# ជម្ងឺខូចតម្រងនោមដែលមានលក្ខណរ៉ាំរ៉ៃអាចបណ្តាលឲ្យខូចបេះដូង
## Chronic Kidney Disease Can Damage Heart

ជម្ងឺតម្រងនោមកើតឡើងនៅពេលដែលរាងកាយមនុស្សយើង ពុំអាចចម្រាញ់បញ្ចេញជាតិទឹក និងជាតិមិណេរាលឲ្យបានស្មើគ្នា។ នៅពេលនោះ តម្រងនោមពុំអាចមានលទ្ធភាពនឹងបញ្ចេញជាតិកាកសំណល់ពីក្នុងរាងកាយទៅក្រៅបានឡើយ។

យោលទៅតាមគ្រឹស្ថានជាតិខាងជម្ងឺខូចថតម្រងនោមដែលហៅថា National Kidney Foundation បានឲ្យដឹងថា ជម្ងឺតម្រងនោមដែលពុំបានព្យាបាល អាចធ្វើឲ្យលើសឈាម (សម្ពាធឈាមខ្លាំង) ដែលជាកត្តាមួយ អាចបណ្តាលឲ្យខូចបេះដូងនិងឆ្អឹង។

ប្រសិនបើ ជម្ងឺខូចតម្រងនោមកាន់តែមានលក្ខណៈធ្ងន់ធ្ងរខ្លាំងឡើង វាអាចបណ្តាលឲ្យមានជាតិកាកសំណល់ កកាញ់ កាន់តែច្រើន នៅក្នុងរាងកាយ រហូតដល់ធ្វើឲ្យមនុស្សយើងធ្លាក់ខ្លួនឈឺជាទម្ងន់។  ជម្ងឺខូចតម្រងនោមនេះ អាចបណ្តាលមកពីជម្ងឺទឹកនោមផ្អែម, ពីពូជដែលធ្លាប់មានជម្ងឺខូចតម្រងនោម, និងជម្ងឺលើសឈាម។

អ្នកដែលអាចមានជម្ងឺខូចតម្រងនោមរ៉ាំរ៉ៃនេះ ជាងគេ គឺអស់លោកចាស់ទុំ, ស្ត្រី រួមទាំងជនជាតិស្បែកខ្មៅ, ជនជាតិពីកោះប៉ាស៊ីហ្វិក, ជនជាតិអាមេរិកាំង-ឥណ្ឌាន, និងជនជាតិស្ពែនីស។

តែស៍ ដែលអាចធ្វើឲ្យដឹង ថាមានជម្ងឺខូចតម្រងនោម ឬពុំមាន គឺតែស៍ពិនិត្យកម្លាំងឈាមរត់, ពិនិត្យទឹកនោម, និងពិនិត្យជាតិ serum creatinine។  ការធ្វើតែស៍ឲ្យបានដឹងមុន ជាកត្តាមួយ អាចជួយព្យាបាល កុំឲ្យតម្រងនោមខូច ឈប់ដើរទាន់ ដែលពាក្យអង់គ្លេស ហៅថា Kidney Failure និងជាកត្តា ដែលត្រូវការលាងឈាម ដែលហៅថា Kidney Dialysis ឬប្តូរតម្រងនោមថ្មី។

នៅថ្ងៃអង្គារ៍ទី 24 ខែ តុលា ឆ្នាំ 2006 ខាងមុខនេះ គ្រឹស្ថានជាតិខាងជម្ងឺខូចតម្រងនោម ហៅថា National Kidney Foundation ព្រមទាំងកម្មវិធីសុខភាពសហគមខ្មែរ 2010 នៃមណ្ឌលសុខភាពសហគមក្រុងឡូវែល នឹងរៀបចំធ្វើជាទិវាពិនិត្យជម្ងឺខូចតម្រងនោមមួយដោយឥតគិតថ្លៃមួយនៅមណ្ឌល Mercier Center អស័យដ្ឋាយ លេខ 21 Market St. ក្នុងទីក្រុងឡូវែល។ ដូច្នេះ សូមអញ្ជើញអស់លោក-លោកស្រីទៅពិនិត្យឲ្យបានច្រើនកុករ។

ចំពោះពត៌មានបន្ថែមស្ដីអំពីជម្ងឺខ្សោយតម្រងនោម សូមមេត្តាអានវិបសៃរបស់ គ្រឹស្ថានជាតិខាងជម្ងឺខ្សោយតម្រងនោម ហៅថា National Kidney Foundation www.kidney.org ឬប្រសិនបើមានបំណាងចង់ជ្រាបច្បាស់អំពីទិវាពិនិត្យជម្ងឺខ្សោយតម្រងនោម នៅទីក្រុងឡូវែល សូមមេត្តាទូរស័ព្ទទៅ កម្មវិធីសុខភាពសហគមខ្មែរ 2010 នៃមណ្ឌលសុខភាពសហគមក្រុងឡូវែល ដែលមានលេខ (978) 746-7829។

*អត្ថបទនេះ ដកស្រង់មួយចំណែកនិងបកប្រែចេញពី Healthfinder ដែលជាកម្មវិធីនៃក្រសួងសុខភាពនិងមនុស្សធម៌នៃសហរដ្ឋអាមេរិក (Department of Health and Human Services) ដោយ មណ្ឌលមេត្តាសុខភាពនៃមណ្ឌលសុខភាពសហគមន៍ក្រុងឡូវែល, 135 Jackson ST. Lowell, MA 01852 ។*

http://www.healthfinder.gov/news/newsstory.asp?docid=534520